**សេចក្តីថ្លែងការណ៍របស់**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និង**
**សហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងសម័យប្រជុំលើកទី៨១ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ក្រោមមូលបទ**
**«ស្តារទំនុកចិត្តឡើងវិញ គ្រប់គ្រងបរិវត្តកម្ម៖ អង្គការសហប្រជាជាតិដែល**
**សម្រេចលទ្ធផលសម្រាប់ទាំងអស់គ្នា»**
ទីក្រុងញូវយ៉ក ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦

**ឯកឧត្តមប្រធានមហាសន្និបាត,**
**លោកជំទាវ ឯកឧត្តម,**
**គណៈប្រតិភូដ៏ឧត្តុង្គឧត្តម**

1. ខ្ញុំសូមអបអរសាទរយ៉ាងកក់ក្តៅបំផុតចំពោះ ឯកឧត្តមបណ្ឌិត Khalilur Rahman ដែលបានជាប់ឆ្នោតជាប្រធានសម័យប្រជុំលើកទី៨១ នៃមហាសន្និបាតអង្គការសហប្រជាជាតិ។ កម្ពុជានឹងគាំទ្រយ៉ាងពេញទំហឹងចំពោះឯកឧត្តម ក្នុងពេលដឹកនាំការងារក្រោមមូលបទដ៏សមស្រប តាមកាលៈទេសៈគឺ «**ការស្តារឡើងវិញនូវទំនុកចិត្ត និងការគ្រប់គ្រងបរិវត្តកម្ម៖ អង្គការសហប្រជាជាតិដែលសម្រេចបានលទ្ធផលសម្រាប់ទាំងអស់គ្នា**»។

2. ខ្ញុំសូមកោតសរសើរចំពោះការដឹកនាំដ៏សកម្មរបស់លោកជំទាវ Annalena Baerbock ក្នុងអំឡុងសម័យប្រជុំលើកទី៨០ នៃមហាសន្និបាតអង្គការសហប្រជាជាតិ។

3. ខ្ញុំមានកិត្តិយសសូមសម្តែងការគោរពដ៏ជ្រាលជ្រៅដល់ឯកឧត្តមអគ្គលេខាធិការ António Guterres ចំពោះការដឹកនាំដ៏ស្វាហាប់ និងការបំពេញភារកិច្ចប្រកបដោយស្មារតីលះបង់ខ្ពស់ជូនអង្គការសហប្រជាជាតិក្នុងអាណត្តិទាំងពីររបស់ឯកឧត្តម ក៏ដូចជាការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះពហុភាគីនិយម សន្តិភាព និងសន្តិសុខ ការអភិវឌ្ឍប្រកបដោយចីរភាព គោលការណ៍ និងគោលបំណងនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ក្នុងអំឡុងទសវត្សរ៍ដែលពោរពេញទៅដោយភាពរឹករវ និងបរិវត្តកម្មយ៉ាងជ្រាលជ្រៅ។

**ឯកឧត្តមប្រធាន**

4. កាលពី៨១ ឆ្នាំមុន ក្រោយពីរងការបំផ្លិចបំផ្លាញនៃសង្គ្រាមលោកលើកទី២ បណ្តារដ្ឋដែលបានបង្កើតអង្គការសហប្រជាជាតិរបស់យើងនេះ បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំថា ត្រូវតែ«ជួយសង្គ្រោះមនុស្សជំនាន់ក្រោយឱ្យរួចផុតពីគ្រោះមហន្តរាយនៃសង្គ្រាម»។

5. ចាប់តាំងពីឆ្នាំ១៩៤៥មក ការប្តេជ្ញាចិត្តនេះនៅតែមានសារៈសំខាន់យ៉ាងខ្លាំងរហូតដល់ពេលបច្ចុប្បន្ន។ ទោះបីជាពិភពលោកបានរួចផុតពីសង្គ្រាមលោកថ្មីមួយទៀតរហូតមកដល់ពេលនេះក៏ដោយ ក៏ជម្លោះប្រដាប់អាវុធនៅតែបន្តបង្កទុក្ខវេទនាដ៏ធ្ងន់ធ្ងរដល់មនុស្សជាតិនៅតាមតំបន់ជាច្រើន។ ទន្ទឹមនេះ ការ

ប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ ការប្រែប្រួលអាកាសធាតុ វិសមភាពដែលកាន់តែរីកធំឡើង ការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស និងការគំរាមកំហែងឆ្លងដែន កំពុងដាក់សម្ពាធកាន់តែខ្លាំងឡើងលើសន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

6. នៅពេលដែលកិច្ចសហប្រតិបត្តិការអន្តរជាតិមានភាពចាំបាច់ជាងពេលណាៗទាំងអស់នោះ ទំនុកចិត្តរវាងប្រជាជាតិទាំងឡាយកំពុងរងការសាកល្បង ខណៈដែលជំនឿទៅលើស្ថាប័នពហុភាគី និងសមត្ថភាពរបស់ស្ថាប័នទាំងនោះក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមជារួម កំពុងតែរងសម្ពាធកាន់តែខ្លាំងឡើង។

**ការឆ្លើយតបរបស់យើង មិនអាចជាការដកថយនោះទេ**

7. **ពិភពលោកត្រូវការអង្គការសហប្រជាជាតិកាន់តែខ្លាំងជាងមុន**។ ប៉ុន្តែពិភពលោកក៏ត្រូវការអង្គការសហប្រជាជាតិមួយ ដែលទទួលបានការជឿទុកចិត្ត ដោយសារតែមានគោលការណ៍ មានភាពតំណាង មានប្រសិទ្ធភាព និងមានសមត្ថភាពក្នុងការសម្រេចបាននូវគោលបំណង និងគោលការណ៍នានានៃធម្មនុញ្ញរបស់ខ្លួន។

8. **ការជឿទុកចិត្តមិនអាចស្តារឡើងវិញតែតាមការប្រកាសលើក្រដាស ឬពាក្យសម្ដីនោះទេ**។ ការទុកចិត្តគឺបានមកពីសង្គតិភាព៖ នោះគឺការគោរពតាមការប្តេជ្ញាចិត្ត ការគោរពច្បាប់អន្តរជាតិ ហើយជម្លោះត្រូវបានដោះស្រាយតាមមធ្យោបាយសន្តិវិធី។

9. សមភាពអធិបតេយ្យត្រូវតែបន្តនៅជាគោលការណ៍គ្រឹះនៃទំនាក់ទំនងអន្តរជាតិ។ ធម្មនុញ្ញអង្គការសហប្រជាជាតិមិនបានកំណត់ស្តង់ដារមួយសម្រាប់ប្រទេសដែលមានអំណាចខ្លាំង និងស្តង់ដារមួយទៀតសម្រាប់ប្រទេសដែលមិនសូវមានអំណាចនោះទេ។ រដ្ឋសមាជិកទាំងអស់ មិនថាធំឬតូច សុទ្ធតែមានភាពស្មើគ្នានៅចំពោះមុខធម្មនុញ្ញអង្គការសហប្រជាជាតិ និងត្រូវគោរពតាមកាតព្វកិច្ចដែលបានកំណត់ដោយធម្មនុញ្ញ។

**ឯកឧត្តមប្រធាន,**

10. កម្ពុជាយល់ច្បាស់អំពីតម្លៃនៃទំនុកចិត្ត ដោយផ្អែកលើប្រវត្តិសាស្ត្ររបស់ខ្លួនផ្ទាល់។ ប្រទេសរបស់យើងបានឆ្លងកាត់ជម្លោះ ការប្រល័យពូជសាសន៍ ការបែកបាក់ និងទុក្ខវេទនារបស់ប្រជាជនយ៉ាងធ្ងន់ធ្ងរ អស់រយៈពេលជាច្រើនទសវត្សរ៍។ កម្ពុជាបានកសាងសន្តិភាពឡើងវិញតាមការសន្ទនា ការកសាងជំនឿទំនុកចិត្ត ព្រមទាំងសេចក្តីក្លាហានផ្នែកនយោបាយ និងគតិបណ្ឌិត ដែលស្តែងចេញតាមរយៈ «នយោបាយឈ្នះ-ឈ្នះ» របស់**សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីកម្ពុជា ដែលបាននាំមកនូវការផ្សះផ្សា និងឯកភាពជាតិ។

11. បទពិសោធន៍នេះនៅតែជាកត្តាកំណត់លើវិធីសាស្ត្ររបស់កម្ពុជាក្នុងការធ្វើទំនាក់ទំនងអន្តរជាតិ និងការប្តេជ្ញាចិត្តដោះស្រាយជម្លោះដោយសន្តិវិធី រួមទាំងជម្លោះពាក់ព័ន្ធនឹងព្រំដែនកម្ពុជា-ថៃផងដែរ។

12. ក្នុងស្មារតីនេះ កម្ពុជាសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសហគមន៍អន្តរជាតិ ដែលបានបន្តយកចិត្តទុកដាក់ ចូលរួមចំណែក និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបាននូវដំណោះស្រាយដោយសន្តិវិធី និងយូរអង្វែងចំពោះជម្លោះនេះ។

13. ភាពតានតឹង និងជម្លោះនាពេលថ្មីៗនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជំនឿទុកចិត្តរវាងកម្ពុជា និងថៃ។ ក្រៅពីការធ្វើឱ្យទំនាក់ទំនងមានភាពតានតឹង ជម្លោះនេះបានបន្សល់ទុកនូវស្លាកស្នាមដ៏ជ្រាលជ្រៅ និងយូរអង្វែង រួមទាំងការខូចខាតដល់បេតិកភណ្ឌវប្បធម៌ និងការបន្តគំរាមកំហែងពីសំណាក់គ្រាប់មិនទាន់ផ្ទុះ ជាដើម។

14. ទោះជាយ៉ាងក្តី ភូមិសាស្ត្របានចងភ្ជាប់ប្រទេសយើងជាមួយគ្នា។ ក្នុងនាមជាអ្នកជិតខាងអចិន្ត្រៃយ៍ ប្រទេសទាំងពីរត្រូវរួមរស់ក្បែរគ្នាជានិច្ច ហើយសន្តិភាព ស្ថិរភាព និងវិបុលភាពរបស់ប្រជាជនយើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា។ ដូច្នេះ ការកសាងទំនុកចិត្តឡើងវិញ មិនមែនគ្រាន់តែជារឿងដែលយើងចង់បានប៉ុណ្ណោះទេ ប៉ុន្តែវាជាកត្តាចាំបាច់សម្រាប់អនាគតនៃទំនាក់ទំនងទ្វេភាគី និងសម្រាប់ការយកចិត្តទុកដាក់រួមរបស់យើង ដែលចង់មានសន្តិភាពយូរអង្វែង និងទំនាក់ទំនងជាប្រទេសជិតខាងល្អនឹងគ្នា។

**15. សម្រាប់កម្ពុជា ការស្តារទំនុកចិត្តឡើងវិញត្រូវតែផ្អែកលើការប្តេជ្ញាចិត្តជាក់ស្តែង។**

16. នេះជាការចាំបាច់ដែលត្រូវមានការអនុវត្តប្រកបដោយប្រសិទ្ធភាព ពេញលេញ និងសុឆន្ទៈ ចំពោះរាល់ការព្រមព្រៀងគ្នា ក្នុងនោះរួមមានសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ កុងសង់ស៊ីសហ្វ៊ូសៀន (Fuxian Consensus) និងជាពិសេសសេចក្តីប្រកាសរួម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដែលភាគីទាំងពីរបានប្តេជ្ញាចិត្តបដិសេធការគំរាមកំហែង ឬការប្រើកម្លាំង និងការគោរពខណ្ឌសីមាព្រំដែនអន្តរជាតិ ក៏ដូចជាការអនុវត្តវិធានការជាក់ស្តែងដើម្បីកាត់បន្ថយភាពតានតឹង កសាងទំនុកចិត្តឡើងវិញ និងជំរុញប្រក្រតីភាពទំនាក់ទំនងទ្វេភាគី។

17. ក្នុងចំណោមវិធានការទាំងនេះ ការចាប់ផ្តើមឡើងវិញជាបន្ទាន់នូវការងារវាស់វែង និងខណ្ឌសីមាព្រំដែនរបស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែន នឹងរួមចំណែកយ៉ាងសំខាន់ដល់ការដោះស្រាយបញ្ហាទាមទារនានា ដែលនៅសេសសល់ពាក់ព័ន្ធនឹងព្រំដែន និងការបង្កើតខ្សែព្រំដែនមួយដ៏ច្បាស់លាស់ដែលភាគីទាំងពីរទទួលស្គាល់ទៅវិញទៅមក ដោយអនុលោមតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់រវាងប្រទេសទាំងពីរ។ អ្វីដែលមានសារៈសំខាន់ដូចគ្នាដែរ ហើយមានផលប៉ះពាល់ដោយផ្ទាល់លើផ្នែកមនុស្សធម៌ នោះគឺការមិនអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានខ្លួនវិញបានរបស់ប្រជាពលរដ្ឋកម្ពុជាជាង ២០,០០០នាក់ ដោយសារការបន្តកាន់កាប់ ការរារាំងរបស់កម្លាំងយោធាថៃ។ ដូចដែលអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានលើកឡើងនៅពេលចុះទៅពិនិត្យតំបន់ព្រំដែនកាលពីខែកក្កដាកន្លងទៅថា «ពួកគេត្រូវការ និងសមទទួលបាននូវការអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ»។

18. ដូចគ្នានេះដែរ ការបញ្ឈប់សកម្មភាពទាំងឡាយនៅក្នុងទឹកដីដែលត្រូវបានកាន់កាប់ ដែលអាចបង្កើត ឬពង្រឹងស្ថានភាពជាក់ស្ដែង (fait accompli) នឹងបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីសុច្ឆន្ទៈ និងការគោរពចំពោះច្បាប់អន្តរជាតិ។

19. ការប្ដេជ្ញាចិត្តដូចគ្នានេះចំពោះដំណោះស្រាយវិវាទដោយសន្តិវិធី ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធីសាស្ត្ររបស់យើង ចំពោះវិវាទលើដែនសមុទ្រកម្ពុជា-ថៃផងដែរ។

20. កាលពីខែឧសភាកន្លងទៅ ប្រទេសថៃបានសម្រេចបញ្ចប់ជាឯកតោភាគីនូវអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ២០០១ ដែលជាក្របខ័ណ្ឌច្បាប់តែមួយគត់បង្កើតឡើងសម្រាប់ប្រទេសទាំងពីរធ្វើជាមូលដ្ឋានដោះស្រាយវិវាទដែនសមុទ្រ បើទោះបីជាយើងបានអំពាវនាវកុំឱ្យថៃធ្វើបែបនេះក៏ដោយ។ ហេតុនេះកម្ពុជាក៏ត្រូវបង្ខំចិត្តផ្ដល់សេចក្ដីទុកចិត្តទៅលើស្ថាប័ន ដែលប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់អន្តរជាតិដោយបានផ្ដួចផ្ដើមនីតិវិធីផ្សះផ្សាដោយបង្ខំ ក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ (UNCLOS)។

21. ដូចដែល**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីរបស់យើង បានថ្លែងនៅក្នុងសុន្ទរកថាពិសេសកាលពីខែមិថុនាកន្លងទៅថា «យើងបានប្រកាន់យកវិធានការនេះ ដើម្បីការពារអធិបតេយ្យ និងសិទ្ធិលើដែនសមុទ្ររបស់កម្ពុជាស្របតាមច្បាប់អន្តរជាតិ។ កម្ពុជាតែងតែស្វែងរកដំណោះស្រាយវិវាទជាមួយប្រទេសជិតខាងដោយសន្តិវិធី។ យើងបន្តស្វែងរកទំនាក់ទំនងជាមួយប្រទេសថៃដែលផ្អែកលើសន្តិភាព កិច្ចសហប្រតិបត្តិការ និងការគោរពគ្នាទៅវិញទៅមក។ ទាំងកម្ពុជា និងថៃ សុទ្ធតែនឹងទទួលបានផលប្រយោជន៍ពីដំណោះស្រាយដ៏យុត្តិធម៌ និងយូរអង្វែង ដែលសម្រេចបានក្រោមការណែនាំរបស់អ្នកជំនាញអន្តរជាតិផ្នែកផ្សះផ្សា និងស្របតាមច្បាប់អន្តរជាតិ»។

22. ក្នុងន័យនេះ កម្ពុជាសូមថ្លែងអំណរគុណចំពោះគណៈកម្មការផ្សះផ្សា ដែលបានបង្ហាញនូវឆន្ទៈដ៏មុតមាំក្នុងការជួយភាគីទាំងពីរដោះស្រាយវិវាទដោយសន្តិវិធី ក្នុងឱកាសកិច្ចប្រជុំលើកទី១ នៅសិង្ហបុរី កាលពីដើមខែនេះ។

23. តម្លៃនៃដំណើរការផ្សះផ្សាគួរតែត្រូវបានចាត់ទុកថាជាឱកាសដ៏មានអត្ថន័យមួយ ដើម្បីផ្សះផ្សាទំនាស់ កសាងទំនុកចិត្តឡើងវិញ និងបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ទំនាក់ទំនងប្រកបដោយសន្តិភាព និងស្ថាបនារវាងប្រទេសទាំងពីរ។

**ឯកឧត្តមប្រធាន,**

24. សំណួរមិនមែនស្ថិតត្រង់ថាតើពិភពលោករបស់យើងកំពុងផ្លាស់ប្ដូរឬអត់នោះទេ ប៉ុន្តែគឺថាតើយើងអាចរួមគ្នាធ្វើឱ្យការផ្លាស់ប្ដូរនោះប្រែក្លាយទៅជាកាលានុវត្តភាព ជាជាងការបែកបាក់គ្នា និងអសន្តិសុខដែរឬទេ។

25. បច្ចេកវិទ្យាបានផ្ដល់មកទាំងសក្ដានុពលវិជ្ជមាន និងហានិភ័យ។ បញ្ញាសិប្បនិម្មិត និងនវានុវត្តន៍ឌីជីថលអាចជួយពន្លឿនការអភិវឌ្ឍ និងពង្រីកកាលានុវត្តភាព ប៉ុន្តែការប្រើប្រាស់ខុសគោលដៅក៏អាចបង្កើនវិសមភាព អសន្តិសុខ និងឧក្រិដ្ឋកម្មឆ្លងដែនកាន់តែធ្ងន់ធ្ងរផងដែរ។

26. ការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាបានក្លាយជាអាទិភាពដ៏សំខាន់បំផុតមួយរបស់ជាតិយើង។

27. កម្ពុជាបានពង្រឹងក្របខ័ណ្ឌច្បាប់ និងស្ថាប័នរបស់ខ្លួន ព្រមទាំងបង្កើនប្រតិបត្តិការអនុវត្តច្បាប់ប្រឆាំងនឹងទីតាំងឆបោក និងបណ្ដាញឧក្រិដ្ឋជនដែលនៅពីក្រោយសកម្មភាពទាំងនោះ ដោយទទួលបានលទ្ធផលជាក់ស្តែងដែលមិនអាចប្រកែកបាន។

28. ប៉ុន្តែគ្មានប្រទេសណាមួយអាចទទួលបានជោគជ័យដោយឯកឯងនោះទេ។ បណ្ដាញឧក្រិដ្ឋជនធ្វើប្រតិបត្តិការឆ្លងកាត់ព្រំដែន ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែរឹងមាំ។ នៅសប្តាហ៍នេះ កម្ពុជាបានរៀបចំដោយជោគជ័យនូវសន្និសីទអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលសហការរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកបញ្ហាគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) និងអង្គការប៉ូលីសអន្តរជាតិ (INTERPOL) ព្រមទាំងស្ថាប័នផ្សេងទៀត។ សន្និសីទនេះបានអំពាវនាវឱ្យមានសកម្មភាពរួមគ្នា និងការសម្របសម្រួលទាំងនៅកម្រិតជាតិ តំបន់ និងសកលលោក ដើម្បីទប់ស្កាត់ និងលុបបំបាត់ឧក្រិដ្ឋកម្មនេះ។

**ឯកឧត្តមប្រធាន,**

29. កម្ពុជាមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ នៅថ្ងៃទី១៥ និង១៦ ខែវិច្ឆិកា។ ជិត៣០ឆ្នាំបន្ទាប់ពីកិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្រនៅទីក្រុងហាណូយ ការជួបជុំជាថ្មីនៃគ្រួសារហ្វ្រង់កូហ្វូនីនៅអាស៊ីនេះមានសារៈសំខាន់ជាពិសេស។ កិច្ចប្រជុំនេះបង្ហាញនូវភាពរស់រវើករបស់សហគមន៍ហ្វ្រង់កូហ្វូនី ឆ្លងហួសព្រំដែនទ្វីប និងភាពខុសគ្នាផ្នែកវប្បធម៌។

30. មូលបទនៃកិច្ចប្រជុំកំពូល «រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង» ក៏ដូចជាមូលបទនៃសម័យប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំនេះ បានលើកពីភាពចាំបាច់រួមមួយ៖ ការស្តារទំនុកចិត្ត និងការវិនិយោគឡើងវិញលើសន្តិភាព គឺជាការពង្រឹងគ្នាទៅវិញទៅមក។

31. ក្រៅពីការលើកស្ទួយភាសាបារាំង កម្ពុជាមានបំណងនឹងធ្វើឱ្យកិច្ចប្រជុំកំពូលនេះក្លាយជាឱកាសនៃការខិតចូលគ្នារវាងប្រជាជននៃទ្វីបទាំងអស់ ជុំវិញតម្លៃរួម៖ សន្តិភាព ការគោរពភាពចម្រុះបែប ការសន្ទនារវាងវប្បធម៌ សាមគ្គីភាព ការយោគយល់គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។

32. វត្តមានរបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនឹងផ្តល់ឱ្យកិច្ចប្រជុំកំពូលនេះនូវសារៈសំខាន់ខាងនយោបាយដ៏ពេញលេញមួយ ហើយនឹងធ្វើឱ្យរាជធានីភ្នំពេញក្លាយជាវេទិកាសំខាន់សម្រាប់ការសន្ទនារវាងប្រជាជាតិនានា។ ព្រះរាជាណាចក្រនៃប្រាង្គប្រាសាទអង្គរនឹងស្វាគមន៍ភ្ញៀវកិត្តិយសទាំងអស់ ជាមួយនឹងបដិសណ្ឋារកិច្ចដ៏ពិសេសរបស់ខ្លួន។

**ឯកឧត្តមប្រធាន**

33. យើងមិនអាចស្តារពិភពលោកសម័យមុនឡើងវិញបានទេ ហើយនោះក៏មិនគួរជាមហិច្ឆតារបស់យើងដែរ។

34. ការទទួលខុសត្រូវរបស់យើងគឺពង្រឹងនូវទំនុកចិត្តរបស់យើងលើសមត្ថភាពរួមក្នុងការដឹកនាំពិភពលោកនាពេលអនាគត។

35. ដើម្បីស្តារទំនុកចិត្តឡើងវិញ យើងត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍ដូចគ្នាសម្រាប់ទាំងអស់គ្នា។ ដើម្បីគ្រប់គ្រងបរិវត្តកម្ម យើងត្រូវតែធានាថា វឌ្ឍនភាពផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា។

36. ដើម្បីឱ្យអង្គការសហប្រជាជាតិផ្តល់លទ្ធផលសម្រាប់ទាំងអស់គ្នា រដ្ឋសមាជិកគ្រប់រូប មិនថាធំឬតូច អភិវឌ្ឍន៍ឬកំពុងអភិវឌ្ឍ ហើយសេចក្តីថ្លៃថ្នូរ សំឡេង និងអនាគតរបស់ខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអង្គការនេះ។

37. កម្ពុជានឹងបន្តធ្វើការជាមួយរដ្ឋសមាជិកទាំងអស់ឆ្ពោះទៅរកគោលដៅនេះ ដូចដែលខ្លួនបានធ្វើតាមរយៈការដាក់ពង្រាយកងកម្លាំងរក្សាសន្តិភាពជាង ១០.០០០នាក់ ចូលរួមប្រតិបត្តិការរក្សាសន្តិភាពក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ។

*សូមអរគុណចំពោះការយកចិត្តទុកដាក់របស់ឯកឧត្តម លោកជំទាវ!*